# ឧស្សាហកម្មដែកនៅ កម្ពុជាសម័យបុរាណ (ភាគ១)

នៅក្នុងអត្ថបទមុន[១] បានបង្ហាញអំពីការរៀបរាប់ ពិពណ៌នាអំពីដំណើរការ និង ដំណាក់កាលនៃការផលិតលោហៈនៅសម័យបុរាណរួចមកហើយ។ ចំពោះ អត្ថបទថ្មី នេះ យើងខ្ញុំនឹងបន្ត អំពីដំណើរការនៃការផលិតដែក ករណីសិក្សាក្នុងប្រទេសកម្ពុជាវិញម្តង។

តាមរយៈឯកសារចងក្រង ដោយបណ្ឌា ជនជាតិបារាំង បានបង្ហាញចាប់ពីឆ្នាំ ១៨៥០ រហូតដល់១៩៤៥ គេប្រទះឃើញនៅមានអ្នកស្លដែកដែលរស់នៅជាសហគមន៍ តូចៗនៅ តំបន់ខាងជើងនៃប្រទេសកម្ពុជា ដែលបច្ចុប្បន្នក្នុង ខេត្តកំពង់ធំ និង ព្រះវិហារ ដូចជានៅ តំបន់ ភ្នំដែក រវៀង ឆែប និង មូរព្រៃ ជាដើម ។ ការស្លដែកនោះ មានលក្ខណៈបុរាណ ពោលគឺការស្លរ៉ែដែកដោយរំលាយនៅក្នុងចង្រ្កានទាប[២]។ អ្នកដែលស្លនោះ គឺជនជាតិកួយ ពុំមែនជាខ្មែរ ហើយសហគមន៍របស់កួយទាំងនោះ ស្ថិតនៅក្នុងព្រៃស្រោងដាច់ស្រយាល។ មិនយូរប៉ុន្មាន ក្រោយឆ្នាំ ១៩៤៥មក កួយក៏លែង ស្ល ដែកតាមរបៀបបុរាណនោះ ហើយ ក៏ បានបោះបង់ ការងារស្លដែករបស់ខ្លួន នោះដែរ ។ តទៀតទៅ លែងមានតំណែងឆាយ[៣]ថ្មីទៀតហើយ។ វិជ្ជាស្លដែកពុំបានបន្តទៅទៀតទេ ហើយក៏បាត់បង់ជាស្ថាពរទៅ[៤]។ កត្តា ដែលនាំឲ្យកួយលែងស្លគឺដោយសារតែ លំហូរចូលដែកបរទេស មានតម្លៃថោកជាង ដែល គេនាំចូលមកពី ព្រៃនគរ សិង្ហបុរី និងចិន ជាដើម[៥]។ សព្វថ្ងៃនេះ យើងឃើញមានតែ សំណល់នៃការស្លដែក ដូចជា អាចមន៍ដែក, បំពង់ខ្យល់ ល ដែលបានបន្សល់ទុកនៅទីតាំង ផ្ទាល់ ពាសពេញព្រៃ។

---

[១] សូមអាន អត្ថបទមុន https://khmercivilization.ams.com.kh/detail/35958

[២] ចង្រ្កានទាប ដែលអ្នកស្រុកកួយ ហៅថា សន្ទូង

[៣] ឆាយ មានតួនាទីជាគ្រូអាចារ្យ ដែលដឹកនាំ ដំណើរនៃការស្លដែក និង ពីធីសាសនារបស់កួយ។

[៤] Dupaigne 2006, p. 191.

[៥] Dupaigne 1992, p. 15.

អត្ថបទដោយ៖ អេង តុលា

ប្រទេសខ្មែរមិនខុសអ្វីពីប្រទេសចាស់ៗនៅលើលោក នេះដែរ គឺគ្រាន់តែថានៅតំបន់បណ្តាប្រទេសមជ្ឈឹមបូព៌ាដូចជា អេហ្ស៊ីប អ៊ីរ៉ាក់ និង អ៊ីរ៉ង់ការលេចឡើងនៃការប្រើប្រាស់ដែក ជំនួសសំរិទ្ធ មានអាយុកាលចំណាស់លើសពី៣០០០ឆ្នាំ មុនគ.ស.[៦] រីឯ ការលេចឡើងនៃការប្រើប្រាស់ដែក នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដីគោករួមទាំងនៅ កម្ពុជា គឺស្ថិតនៅយុគដែក ដែលមានអាយុកាលចន្លោះ ៥០០ ឆ្នាំ មុនគ.ស. និង ៥០០ឆ្នាំនៃគ.ស.[៧]។ ដែកមានប្រសិទ្ធិភាពច្រើនជាងសំរិទ្ធក្នុងការផលិតជាឧបករណ៍កសិកម្ម, ឧបករណ៍ប្រម៉ាញ់, ឧបករណ៍សាងសង់ និងក្លាយជា អាវុធសម្រាប់ចម្បាំង ពង្រីកទឹកដី។

សំណួរដែលអ្នកស្រាវជ្រាវលើប្រធានបទមួយនេះ តែងតែ ចោទសួរតើ ការស្លដែកនៅប្រទេសកម្ពុជាសម័យបុរាណនេះចេញពីណា? តើកើតឡើងដោយជនជាតិ នៅប្រទេសកម្ពុជាផ្ទាល់ ឬមួយក៏នាំមកដោយមនុស្សឥណ្ឌា ដែលមកស៊ីរស់នៅតំបន់នេះ ឬមកពី វៀតណាមផ្នែកខាងត្បូងតាមឆ្នេរសមុទ្រ នៅ រវាងដើមគ.ស. ឬមួយក៏បច្ចេកទេសនេះចូលមកពីទិសខាងជើងតាមផ្លូវគោកមកពីប្រទេសចិន?

សូមរំលឹកដែរថា នៅប្រទេសឥណ្ឌា ដែកចាប់ផ្តើមឃើញមានឡើងនៅសម័យប្រហាក់ប្រហែលគ្នានេះដែរ ហើយដែកនោះ ប្រហែលជាចូលមកពី មជ្ឈឹមបូព៌ា រវាងស.វ.ទី១០ មុនគ.ស.។ រីឯនៅប្រទេសចិន ដែកដែលបានមកពីការរំលាយរ៉ែចាប់មានឡើងនៅរវាងឆ្នាំ ១១០០មុនគ.ស. ពោលគឺប្រហាក់ប្រហែលនឹងនៅឥណ្ឌា ហើយប្រហែលឆ្លងមកពីមជ្ឈឹបូព៌ាដូចគ្នាដែរ[៨]។

នៅរវាងដើមគ.ស.ខ្មែរចាប់ផ្តើមទទួលឥទ្ធិពលពីឥណ្ឌា តាមរយៈមនុស្សឥណ្ឌាដែលមកដល់ហ្វូណន់។ ជាមួយគ្នានោះ កម្ពុជាក៏ទទួលឥទ្ធិពលពីចិនខាងត្បូងដែរ។ តាមរយៈសម្មតិកម្មដោយ លោក Bernard Dupaigne បានលើកឡើងជាទ្រឹស្តីថា បច្ចេកទេសដែល

---

[៦] Dupaigne 1992, p. 13-24.

[៧] Higham 2014, p. 197-198.

[៨] Dupaigne 1992, p. 19.

អត្ថបទដោយ៖ អេង តុលា

ឃើញមានការប្រើប្រាស់ក្នុងប្រទេសកម្ពុជារបស់ជនជាតិកួយ មានប្រភពមកពីចិន ដោយលើកជដែក អំពីបច្ចេកទេសសិតសំរិទ្ធ និងបច្ចេកទេសផលិតកុលាលភាជន៍នៅលើភ្នំគូលែន ស.វ.ទី១០ អាចជាជនជាតិចិន[៩] ប៉ុន្តែក្រោយមក លោកបានពិចារណាឡើងវិញអំពីសម្មតិកម្មរបស់គាត់ស្ដីពីប្រភពកំណើតនៃលោហកម្មដែករបស់ជនជាតិកួយ ហើយលើកនេះបានភ្ជាប់វាទៅនឹងការប្រើប្រាស់បច្ចេកទេស ដែលមានឥទ្ធិពលមកពីឥណ្ឌា។ សូម្បីតែពិធីបែបសាសនាដែលពាក់ព័ន្ធនឹងការស្ងរបស់ជនជាតិកួយ ក៏មានប្រភពមកពីឥណ្ឌាផងដែរ ដោយឃើញមានការគោរពទេព និងធ្វើរូបពិស្ដុការដែលជាទេពនៃស្ថាបត្យកម្មក្នុងសាសនាហិណ្ឌូ[១០]។ សម្មតិកម្មរបស់លោក Bernard Dupaigne គឺគ្រាន់តែជាផ្នែកមួយនៃ ការស្រាវជ្រាវ នរវិទ្យា ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់ នៅឡើយ ។

ក្រៅពីនេះ ក៏មានអ្នកស្រាវជ្រាវផ្សេងៗទៀត ដែលបន្តធ្វើការសិក្សាអំពីប្រធានបទនេះ តួយ៉ាងតាមរយៈការសិក្សា និងធ្វើកំណាយស្រាវជ្រាវនៅតំបន់ប្រាសាទព្រះខ័ន្ធកំពង់ស្វាយ នៅជុំវិញភ្នំដែក និងនៅឆែប ដែលជា តំបន់ ឧស្សហកម្មសំខាន់នៅ សម័យអង្គរស.វ.ទី១២ និង១៣ នៃគ.ស.។

សរុបជារួមមក ឧស្សាហកម្មដែកដែលមាននៅក្នុងប្រទេសកម្ពុជា លេចឡើងនៅ ចន្លោះ ៥០០ឆ្នាំ មុនគ.ស. និង ៥០០ ឆ្នាំ គ.ស. ប៉ុន្តែពុំដឹងថា នរណាជាអ្នកស្ង និងប្រើប្រាស់បច្ចេកទេសដូចម្ដេចនោះទេ។ ក្រោយមកតាមរយៈឯកសារ ដោយបណ្ដាជនជាតិបារាំង ចាប់ពីឆ្នាំ ១៨៥០ រហូតដល់១៩៤៥ បានបង្ហាញអំពីការស្ងដែកនៅ ភាគខាងជើងប្រទេសកម្ពុជា ដោយជនជាតិកួយប្រើប្រាស់បច្ចេកទេសដែលមានឥទ្ធិពលមកឥណ្ឌា ទាំងបច្ចេកទេស និងជំនឿសាសនា ប៉ុន្តែបើទោះបី កួយទទួលឥទ្ធិពលពីឥណ្ឌាមែន ក៏បច្ចេកទេសស្ង និងជំនឿក៏ពុំ

---

[៩] Ibid,22.

[១០] Dupainge 2016.

ដូចនៅឥណ្ឌាទាំងស្រុងដែរ។ នេះគឺគ្រាន់ជាសម្មតិកម្មមួយរបស់លោក Bernard Dupaigne ដែលទាមទារការស្រាវជ្រាវជាបន្តបន្ទាប់ឲ្យកាន់តែស៊ីជម្រៅទៀត។

ការស្ទូដែកនៅកម្ពុជា ចុងក្រោយគេ គឺនៅឆ្នាំ ១៩៤៩ ហើយក្រោយពីឆ្នាំនោះ មកក៏លែងមានកួយស្ទូដែកទៀតហើយ។ ទាំងបច្ចេកទេស និងវិជ្ជាស្ទូដែកនោះ ក៏លែងមាន និងបាត់បង់រហូតមក។ បច្ចុប្បន្នយើងនៅឃើញមានតែជាងដែកកួយមួយចំនួនដែលបន្តផលិតឧបករណ៍ប្រើប្រាស់ផ្សេងៗ ដែលដែកប្រើប្រាស់នោះ យកពីបំណែកឡាន ឬឧបករណ៍ចាស់ផ្សេងៗលែងមានដែកមកពីការស្ទូទៀតហើយ។

## ឯកសារយោង

DUPAIGNE, Bernard

**1971** « Rapport de voyage d'études à Phnom Dek, 27 Décembre 1969 – 3 Janvier 1970 », *Bulletin des Étudiants de la Faculté d'Archéologie*, 3-4, p. 88-91.

**1987** *Les maîtres du fer et du feu. Étude de la métallurgie du fer chez les Kouy du nord du Cambodge, dans le contexte historique et ethnographique de l'ensemble khmer* (4 vol.), thèse de doctorat, Paris, École des hautes études en sciences sociales.

**1992** « La métallurgie dans l'ancien Cambodge. Travail des dieux, travail des hommes », *Études rurales*, 125-126, p. 13-24.
https://doi.org/10.3406/rural.1992.3350

**2002** « Obtention du fer et rituels chez les métallurgistes du Cambodge », in Société des études euro-asiatiques, *La forge et le forgeron, I. Pratiques et croyances*, Paris, L'Harmattan, Collection Eurasie (11), p. 11-30.

**2006** « Ussāhakamm lohadhātu nau kambujā samǎy purāṇ : nā dī deb, nā dī manuss [La métallurgie dans l'ancien Cambodge. Travail des dieux, travail des hommes] », *Udaya, Journal of Khmer Studies*, 7, p. 177-195.
http://www.yosothor.org/uploads/images/Udaya/UDAYA_ISSUES/Udaya_07/06_Bernard%20Dupaigne_UDAYA07.pdf

HIGHAM, Charles

**2014** *Early Mainland Southeast Asia: From First Humans to Angkor*, Bangkok, River Books, [1ère éd. 2002].

អត្ថបទដោយ៖ អេង តុលា



Fonderie de fer chez les Kouys.



Forgerons kouys.

រូបគំនូរ គូរនៅឆ្នាំ ១៨៨០ ដោយលោក Edgar Boulangier ស្តីអំពី ដំណើរការស្លដែក ពី ថ្មទៅ ដែក ដោយជនជាតិកួយនៅ ភ្នំដែក។

ក. រូបអំពីការដំណើរការនៃការស្លដែក

ខ. ការដំដែក

អត្ថបទដោយ៖ អេង តុលា



រូបថតបង្ហាញពី ឆាយ ម្នាក់នៅភូមិ ហុង ពោធិ ?( Hong Peo). ថតដោយលោក Deloche de Campocasso នៅឆ្នាំ ១៩២៦.






រូបថតបង្ហាញពី ការកសាងចង្រ្កានស្ងដែក កួយ ថតដោយលោក Deloche de Campocasso នៅឆ្នាំ ១៩២៦.

អត្ថបទដោយ៖ អេង តុលា






ឧបករណ៍ របស់ជាងដែកក្លួយ ដែលបន្តនៅជំដែក ធ្វើជា ឧបករណ៍ប្រើប្រាស់ផ្សេងនៅ ស្រុក ឆែប ខេត្ត ព្រះវិហារ។ រូបថត ឆ្នាំ ២០២២.

អត្ថបទដោយ៖ អេង តុលា